# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (Environmental Justice Council)
## កិច្ចប្រជុំលើកទី #3
## ថ្ងៃអង្គារ ទី27 ខែកញ្ញា ឆ្នាំ2022
## ម៉ោង 12:00 ថ្ងៃត្រង់
## <u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ កិច្ចប្រជុំតាមប្រព័ន្ធ Zoom
ឯកសារកិច្ចប្រជុំ៖ របៀបវារៈ ស្លាយ កំណត់ហេតុកិច្ចប្រជុំ (9/15/2022)

**សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន៖**

- Kalila Barnett
- Madeline Fraser Cook
- Melissa Harding-Ferretti
- Cheryll Holley
- Caroline Hon
- Lydia Lowe
- Marcos Luna
- Peter Maathey
- Rishi Reddi
- Ari Zorn

**បុគ្គលិករបស់ការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថាន (EOFEA) ដែលមានវត្តមាន៖** Rishi Reddi, Vallery Cardoso

**របៀបវារៈ៖**

1. មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ
2. ការអនុម័តលើកំណត់ហេតុមុនកិច្ចប្រជុំ និងការប្រកាសហេតុ
3. បទបង្ហាញដោយក្រុមការងារយុត្តិធម៌បរិស្ថាន
   - ការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាជូសេត – Tori Kim
   - ក្រសួងកសិកម្ម – Rebecca Davidson
   - ក្រសួងការពារបរិស្ថាន – Deneen Simpson
   - ក្រសួងសេវាសាធារណៈ – Scott Seigal, Carline Lemoine
   - មជ្ឈមណ្ឌលថាមពលស្អាតរដ្ឋម៉ាសាជូសេត (Massachusetts Clean Energy Center) – Beverly Craig and Jade Lu
   - កម្មវិធីត្រៀមរៀបចំចំពោះភាពងាយរងគ្រោះរបស់ក្រុង – Carrieanne Petrik
4. ការពិភាក្សាបន្ថែមនៃលទ្ធផលការងារ កិច្ចដំណើរការ និងប្រតិបត្តិការរបស់ក្រុមប្រឹក្សា EJC ស្តីពីការវិភាគលម្អិតគ្រប់ជ្រុងជ្រោយលើនិយមន័យនៃ “ប្រជាជនយុត្តិធម៌បរិស្ថាន”
5. សំណួរ/មតិយោបល់ពីសាធារណជន
6. ជំហានបន្ទាប់ និងការលើកវារកាល

កិច្ចប្រជុំបានចាប់ផ្តើមនៅម៉ោង 12:11 ថ្ងៃត្រង់។

**មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ៖**
Rishi បានស្វាគមន៍អ្នកចូលរួម និងផ្តល់ព័ត៌មានអំពីបណ្តាញបកប្រែភាសា និងលទ្ធភាពអាចទទួលបានស្តាយដែលបានបកប្រែរួច។ Rishi បានជូនដំណឹងដល់អ្នកចូលរួមថា កិច្ចប្រជុំនេះនឹងត្រូវបានកត់ត្រា និងបង្ហោះតាមអនឡាញ ព្រមទាំងផ្តល់ទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ និងរបៀបវារៈនៃកិច្ចប្រជុំ។ អ្នកចូលរួមក្នុងកិច្ចប្រជុំបានជ្រាបព័ត៌មានថា យើងប្រហែលជាមិនអាចបញ្ចប់របៀបវារៈទាំងមូលបានទេក្នុងអំឡុងពេលកិច្ចប្រជុំនេះ។ Rishi បានស្រង់វត្តមាននៃសមាជិកក្រុមប្រឹក្សា EJC ។

**ការឯកភាពលើកំណត់ហេតុកិច្ចប្រជុំពីមុន និងការប្រកាសហេតុ៖**
Rishi បានស្នើសុំមតិកែលម្អ និង/ឬការកែប្រែទៅលើកំណត់ហេតុប្រជុំកាលពីកិច្ចប្រជុំថ្ងៃទី27 ខែកញ្ញា។ មិនមានការផ្តល់យោបល់ពីសមាជិកក្រុមប្រឹក្សាទេ។ Rishi បានស្នើសុំញ្ញត្តិដើម្បីអនុម័តលើកំណត់ហេតុទាំងនេះជាមួយនឹងការគាំទ្រញ្ញត្តិនោះ។ Melissa បានស្នើឲ្យអនុម័តលើញ្ញត្តិនោះ។ Cheryll បានគាំទ្រដល់ញ្ញត្តិនោះ។ បន្ទាប់មក Rishi បានហៅឈ្មោះសម្រាប់ការបោះឆ្នោតឯកភាពលើកំណត់ហេតុ។ សមាជិកក្រុមប្រឹក្សាបច្ចុប្បន្នទាំងអស់បានបោះឆ្នោត "គាំទ្រ" ក្នុងការឯកភាពលើកំណត់ហេតុកិច្ចប្រជុំ។

Rishi បានផ្តល់ជូននូវការប្រកាសហេតុដូចខាងក្រោម៖
- ការណែនាំឲ្យស្គាល់បុគ្គលិកថ្មីរបស់ការិយាល័យ EJ របស់ EEA គឺលោកស្រី Carline Lemoine អនុប្រធានសម្រាប់អ្នកសម្របសម្រួលភាគីពាក់ព័ន្ធខាងក្រៅ។ Carline បានផ្តល់ព័ត៌មានអំពីប្រវត្តិរបស់អ្នកស្រី និងការងារដែលអ្នកស្រីបានធ្វើក្នុងអំឡុងពេលដែលអ្នកស្រីស្ថិតនៅក្រសួងសេវាសាធារណៈ (DPU)។
- ធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រ EJ របស់ EEA និងការចេញផ្សាយនាពេលខាងមុខសម្រាប់មតិសាធារណៈ
- ការលុបចោលកិច្ចប្រជុំក្រុមប្រឹក្សា EJ ថ្ងៃទី12 ខែតុលា។ កិច្ចប្រជុំបន្ទាប់នឹងធ្វើឡើងនៅថ្ងៃទី27 ខែតុលា ចាប់ពីម៉ោង 6 ដល់ម៉ោង 8 យប់។

**បទបង្ហាញដោយក្រុមចម្រុះយុត្តិធម៌បរិស្ថាន៖**
ក្រុមការងារ EJ របស់ EEA បានណែនាំខ្លួន។
- Rebecca Davidson, MDAR
- Jorge Ayub, DCR
- Deneen Simpson, MassDEP
- James "Jimmy" Rossignol, DFG
- Danilo Morales, DOER
- Scott Seigal, DPU
- Wayne Wang, EFSB
- Tyler Soleau, CZM (មិនមានវត្តមាន)
- Major Kevin Clayton, MEP (មិនមានវត្តមាន)
- Dominique Pahlavan, GIS
- Tori Kim, MEPA
- Kari Sasportas, OTA
- Carrieanne Petrik, MVP Program

សមាជិកក្រុមការងារ EJ ខាងក្រោមបានបង្ហាញពីទិដ្ឋភាពទូទៅនៃគំនិតផ្តួចផ្តើម EJ កំពូលទាំង 5 បច្ចុប្បន្នរបស់ ការិយាល័យ ឬទីភ្នាក់ងាររបស់ពួកគេ និងផលប៉ះពាល់មួយចំនួនដែលការកំណត់និយមន័យក្រុមប្រជាជន EJ មានទៅលើការងាររបស់ការិយាល័យ ឬទីភ្នាក់ងាររបស់ពួកគេ៖

- Tori Kim, MEPA
- Rebecca Davidson, MDAR
- Deneen Simpson, MassDEP
- Scott Seigal និង Carline Lemoine, DPU
- MassCEC, Beverly Craig និង Jade Lu
- Carrieanne Petrik, MVP Program

Rishi បានស្នើសុំសំណួរពីក្រុមប្រឹក្សា EJ។ Marcos បានថ្លែងអំណរគុណដល់ EJTF ដែលបានផ្តល់បទបង្ហាញ ។ ដោយបាននិយាយថា លោកបានកោតសរសើរដល់ MassCEC ដែលបានលើកឡើងពីការវាស់ស្ទង់លើថវិកាជំនួយ និងបង្ហាញការចាប់អារម្មណ៍អំពីរបៀបដែលភ្នាក់ងារផ្សេងៗធ្វើការតាមដានការវាស់ស្ទង់លើធនធានអ្វីខ្លះដែលត្រូវបានបែងចែក/បញ្ជូនទៅកាន់សង្កាត់ EJ ។ Jade បានឆ្លើយតបថា ពួកគេមានកម្មវិធីសូហ្វវែរគ្រប់គ្រងថវិកាជំនួយផ្ទៃក្នុងដែលពួកគេរួមបញ្ចូលនូវប្រអប់បំពេញព័ត៌មានមួយនៅក្នុងកំណត់ត្រាប្រគល់ជូននីមួយៗ តើគម្រោងនោះកំពុងដំណើរការនៅក្នុងសង្កាត់ EJ ដែរឬអត់ ហើយតើមានគោលដៅពាក់ព័ន្ធនឹងពិពិធភាព សមធម៌ និងបរិយាបន្នដែរឬអត់។
Rishi បានស្នើសុំសំណួរផ្សេងទៀតពីក្រុមប្រឹក្សា EJ ។

អ៊ីម៉ែលរបស់សមាជិកក្រុមការងារ EJ អាចស្វែងរកបាននៅលើគេហទំព័រ EJ  របស់ EEA៖ https://www.mass.gov/service-details/environmental-justice-contacts. ប្រសិនបើមានចំណាប់អារម្មណ៍ EJTF អាចចូលរួមកិច្ចប្រជុំនាពេលខាងមុខបាន ដើម្បីពិភាក្សាបន្ថែម។

Vallery បានស្នើសុំឱ្យផ្អាកកិច្ចប្រជុំ។ Marcos បានស្នើសុំ។ Madeleine បានគាំទ្រ។ Rishi បានហៅឈ្មោះអ្នកចូលរួមដើម្បីធ្វើការបោះឆ្នោត។ សមាជិកបច្ចុប្បន្នទាំងអស់បានបោះឆ្នោតផ្អាកកិច្ចប្រជុំ។

**ការពិភាក្សាបន្ថែមនៃលទ្ធផលការងារ កិច្ចដំណើរការ និងប្រតិបត្តិការរបស់ក្រុមប្រឹក្សា EJC ស្តីពីការវិភាគលម្អិតគ្រប់ជ្រុងជ្រោយលើនិយមន័យនៃ "ប្រជាជនយុត្តិធម៌បរិស្ថាន"៖**
យើងមិនបានពិភាក្សាអំពីរបៀបវារៈនេះក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះទេ។

**សំណួរ/មតិយោបល់ពីសាធារណជន៖**
មិនមានសំណួរផ្សេងទៀតត្រូវបានសាកសួរពីក្រុមប្រឹក្សា EJ ទេ។ Rishi បានសុំអភ័យទោស ដោយសារបញ្ហាបច្ចេកទេស និងការធ្វើបទបង្ហាញ ទើបមិនមានពេលដើម្បីសួរសំណួរពីសាធារណជន។ យើងនឹងទទួលយកសំណួរនៅកិច្ចប្រជុំបន្ទាប់របស់យើង។

**ជំហានបន្ទាប់ និងការលើកវារកាលៈ**
កិច្ចប្រជុំបន្ទាប់គឺនៅថ្ងៃទី27 ខែតុលា ចាប់ពីម៉ោង 6 ដល់ម៉ោង 8 យប់។ របៀបវារៈដែលបានស្នើឡើងគឺត្រូវធ្វើសេចក្តីសម្រេចទៅលើរបាយការណ៍ការងារ និងដំណើរការដែលយើងនឹងសម្រេចបាននូវលទ្ធផលការងារនោះ និងពិភាក្សាលើអ្វីដែលបាត់ពីនិយមន័យនៃចំនួនប្រជាជន EJ ។ របៀបវារៈដែលបានស្នើឡើងអាចត្រូវបានផ្ញើតាមអ៊ីម៉ែលទៅកាន់ Vallery តាមរយៈ vallery.b.cardoso@mass.gov.

កិច្ចប្រជុំត្រូវបានផ្អាកនៅម៉ោង 1:14។